# សេចក្តីប្រកាសព័ត៌មានរួម

## សង្គមស៊ីវិលប្រារព្ធពិធីបុណ្យរំលឹកសំរាប់ជនរងគ្រោះនៃរបបខ្មែរក្រហម
## នៅមុនការចាប់ផ្តើមការជំនុំជម្រះសំណុំរឿងទីពីរនៅបូជនីយដ្ឋានជើងឯក

ភ្នំពេញ, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១១

នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ការជំនុំជម្រះលើសំណុំរឿងទីពីរដែលបានទន្ទឹងរងចាំជាយូរប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមចំនួនបីរូប នឹងចាប់ផ្តើមនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ អង្គការសង្គមស៊ីវិល ដែលបានចូលរួមក្នុងដំណើរការចាប់តាំងពីការចាប់ផ្តើមដំណើរការនោះមក សូមស្វាគមន៍ចំពោះការចាប់ផ្តើមនៃការជំនុំជម្រះសំខាន់បំផុតរបស់ អ.វ.ត.ក ថ្វីបើតុលាការនេះបានចំណាយពេលអស់ជាច្រើនឆ្នាំមុននឹងឈានដល់ការចាប់ផ្តើមសំណុំរឿង០០២ពេលនេះក៏ដោយ។ ដើម្បីឲ្យដំណើរការសំណុំរឿងសំខាន់បំផុតនេះ ប្រកបដោយប្រសិទ្ធិភាព គឺត្រូវចាំបាច់ធានាថា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រព្រឹត្តទៅប្រកបដោយអត្ថន័យ ហើយធានាថាដំណើរការនីតិវិធីរបស់ អ.វ.ត.ក ត្រូវបានធ្វើឡើងប្រកបដោយយុត្តិធម៌ និងប្រកបដោយតម្លាភាព។

ការគាំទ្រដល់ជនរងគ្រោះរបបខ្មែរក្រហម ដែលបានកំពុងចង់បានយុត្តិធម៌ខ្លាំងអស់រយៈពេលច្រើនទសវត្សរ៍មក ហើយ បានត្រូវបានផ្តល់ឲ្យដោយអង្គការសង្គមស៊ីវិលមួយចំនួនដូចជា សមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (ADHOC), សមាគមមេធាវីគ្មានព្រំដែនប្រទេសបារាំង (ASF France), ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា (CDP), លេខាធិការដ្ឋានគណៈកម្មាធិការប្រព្រឹត្តិកម្មអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC), វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ (KID), សមាគមជនរងគ្រោះក្សេមក្សាន្ត (Ksaemksan Victims Association), អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC), និងអង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO)។

ក្នុងខណៈដែលសាលាដំបូងបើកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២ខាងមុខនេះ អង្គការអន្តរការីទាំងនេះបានរៀបចំពិធីមួយនៅបូជនីយដ្ឋានជើងឯក នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១១ ដើម្បីរំលឹកការចាប់ផ្តើមប្រវត្តិសាស្ត្រនៃការជំនុំជម្រះសំណុំរឿងទីពីររបស់សាលាក្តី និងដើម្បីផ្តល់ដល់ជនរងគ្រោះនូវសម្លេងរួមមួយ។ ក្នុងន័យនេះ អ្នករៀបចំសូមគូសបញ្ជាក់ដូចខាងក្រោមៈ

១/ យើងជំរុញឲ្យមានការគិតគូរនុវសារៈសំខាន់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅគ្រប់តំណាក់កាលនៃដំណើរការសំណុំរឿង០០២។ បញ្ហាប្រឈមមួយចំនួនទាក់ទិននឹងការចូលរួមរបស់ជនរងគ្រោះត្រូវបានកត់សំគាល់តាំងពីពេលដំណើរការពីដំបូងមកម្ល៉េះ ហើយក៏ត្រូវដោះស្រាយ និងសម្របសម្រួលឲ្យបានត្រឹមត្រូវ តាមរយៈមធ្យោបាយច្នៃប្រឌិត និងប៉ិនប្រសព្វផ្សេងៗ ដោយមិនត្រូវធ្វើឲ្យប៉ះពាល់សិទ្ធិរបស់ជនរងគ្រោះឡើយ។

២/ ផលប៉ះពាល់នៃដីកាសំរេចបំបែកសកិច្ចដំណើរការនីតិវិធី មិនគួរត្រូវបានប៉ានប្រមាណដោយខ្វះភាពហ្មត់ចត់ ហើយដែលអាចបណ្តាលឲ្យមានផលអវិជ្ជមានបន្តិចម្តងៗនោះឡើយ។ ពីព្រោះថា មានតែដើមបណ្តឹងរដ្ឋប្បវេណីមួយផ្នែកតូចតែប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឲ្យចូលរួមដោយផ្ទាល់ក្នុងការជំនុំជម្រះលើកទីមួយ ហើយនៅតែ

ត្រូវបានមើលឃើញជាបញ្ហា ប្រសិនបើ អង្គជំនុំជម្រះមិនអាចឆ្លើយតបនឹងការសន្យារបស់ខ្លួនក្នុងការអនុញ្ញាតឲ្យជនរងគ្រោះចូលរួមជាក្រុមរួមមួយ ដែលប្រយោជន៍របស់ពួកគេ ចាំបាច់ត្រូវតែពិចារណាឲ្យបានហ្មត់ចត់ទេនោះ។

៣/ យើងសុំឲ្យ អ.វ.ត.ក ពង្រឹងបន្ថែមនូវអាណត្តិសំណង និងវិធានការផ្សេងៗមិនទាក់ទងបច្ចេកទេសតុលាការរបស់ខ្លួន។ ការជំនុំជម្រះ ឌុច កន្លងមក បានគ្រាន់តែផ្តល់នូវសំណងដែលមិនមានលក្ខណៈច្នៃប្រឌិត និងមានកំរិតដែលបានត្រឹមតែធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើនខកចិត្តយ៉ាងខ្លាំង។ ម្យ៉ាងទៀត ការបំបែកសំណុំរឿងទៅជាការជម្រះក្តីផ្នែកតូចៗ នឹងបង្កើតឲ្យមានបញ្ហាប្រឈមថ្មីមួយទៀត និងបង្ហាញនូវភាពមិនច្បាស់លាស់សំរាប់ក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី។ ដូចនេះ តុលាការ ចាំបាច់ត្រូវបញ្ជាក់ពីការប៉ះពាល់នៃការជម្រះក្តីជាផ្នែកតូចៗ ទៅលើអាណត្តិសំណងផងដែរ។

៤/ មានតែបន្តការប្តេជ្ញាចិត្តជាវិជ្ជមាន និងការប្តេជ្ញាផ្តល់ថវិកាដោយម្ចាស់ជំនួយអន្តរជាតិ និងអង្គការសហប្រជាជាតិប៉ុណ្ណោះទេ ដែលជួយធានាឲ្យមានការការជម្រះក្តីប្រកបដោយយុត្តិធម៌ និងឯករាជ្យ ដែលក្នុងនោះ ជនរងគ្រោះក៏ត្រូវបានដាក់បញ្ចូលហើយទស្សនៈរបស់ពួកគាត់ត្រូវបានគិតគូរដោយមធ្យ័ត។ បន្ថែមពីនេះទៀត ការបង្កើន និងការបន្តកិច្ចសហប្រតិបត្តិការ រវាងអង្គការសង្គមស៊ីវិល និងអង្គភាពពាក់ព័ន្ធរបស់ អ.វ.ត.ក ក៏ត្រូវបានចាំបាច់ឲ្យមានផងដែរ។

៥/ ពាក់ព័ន្ធនឹងការជំនុំជម្រះសំណុំរឿង០០២ក្នុងពេលឆាប់ៗនេះ សង្គមស៊ីវិលខកចិត្តចំពោះសំណើសុំថ្លែងបើករបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបដិសេធដោយអង្គជំនុំជម្រះ។ ទស្សនៈ និង ការព្រួយបារម្ភរបស់ដើមបណ្តឹងរដ្ឋប្បវេណី គួរត្រូវដាក់បញ្ចូលជាផ្នែកស្នូលមួយដ៏សំខាន់នៃដំណើរការជំនុំជម្រះ។

៦/ ឯករាជ្យភាពរបស់ អ.វ.ត.ក ត្រូវតែធានា។ ការជ្រៀតជ្រែកខាងនយោបាយណាមួយទៅក្នុងកិច្ចការរបស់សាលាក្តីនេះ ត្រូវតែបញ្ឈប់។ កេរ្តិ៍ដំណែលអនាគតរបស់ អ.វ.ត.ក នឹងត្រូវមើលឃើញថា ជាជោគជ័យ លុះត្រាតែសមាជិកទាំងអស់របស់ អ.វ.ត.ក គោរពគោលការណ៍ជាមូលដ្ឋាននៃឯករាជ្យភាព, សមធម៌, សុច្ចរឹតភាព និងតម្លាភាព។

<u>សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:</u>


| | | |
|---|---|---|
| លោក ធន សារាយ | ប្រធានសមាគមអាដហុក/ប្រធានសម្របសម្រួល CHRAC | ទូរស័ព្ទ: ០១៦ ៨៤០ ០៨៤ |
| លោក សុក សំអឿន | នាយកប្រតិបត្តិនៃអង្គការ CDP | ទូរស័ព្ទ: ០១២ ៩០១ ១៩៩ |
| លោក ជុំ ស៊ីវ៉ាត់ | អនុប្រធានទី១ សមាគមនជនរងគ្រោះក្មេរក្សាន្ត | ទូរស័ព្ទ: ០១២ ៨១២ ៩៦៨ |
| លោក យួន សារ៉ាត់ | ជំនួយការគំរោងនៃអង្គការ TPO | ទូរស័ព្ទ: ០១៧ ៦៦៣ ៨៥៦ |
| លោក Barnabé Nékuie | សមាគម ASF-France | ទូរស័ព្ទ: ០៩៨ ៧៥៣ ៧៥២ |